# ការយល់ដឹងអំពីការគ្រប់គ្រងករណីគ្មានជម្លោះរបស់គម្រោង Medicaid



ប្រព័ន្ធគ្រប់គ្រងករណីគ្មានជម្លោះ (CFCM) ថ្មីរបស់ Rhode Island ត្រូវបានទាមទារដោយគម្រោង Medicaid សម្រាប់អ្នកចូលរួមដែលទទួលបានសេវាកម្ម និងការគាំទ្ររយៈពេលវែង (LTSS) នៅក្នុងបរិបទផ្ទះ និងសហគមន៍ (HCBS)។

ស្វែងយល់បន្ថែមអំពីអ្វីដែលការផ្លាស់ប្តូរនេះមានន័យសម្រាប់មនុស្សចាស់ និងមនុស្សដែលមានពិការភាពផ្នែកបញ្ញា ឬការអភិវឌ្ឍនៅឆ្នាំ 2024។

## តើនេះមានន័យយ៉ាងណាចំពោះខ្ញុំ?

- សេវាកម្មគ្រប់គ្រងករណីរបស់អ្នកត្រូវតែផ្តល់ដោយនរណាម្នាក់ដែលមិនផ្តល់សេវាកម្មជំនួយគាំទ្រដោយផ្ទាល់របស់អ្នកផងដែរ។
- ការគ្រប់គ្រងករណីគឺផ្តោតលើ **អ្នក**។ អ្នកគ្រប់គ្រងករណីរបស់អ្នកនឹងជួយអ្នកស្វែងរកជំនួយគាំទ្រសហគមន៍ ដូច្នេះអ្នកអាចសម្រេចបាននូវគោលដៅដែលអ្នកមានសម្រាប់ជីវិតរបស់អ្នក។

## តើអ្នកណានឹងផ្តល់សេវាកម្មគ្រប់គ្រងករណីរបស់ខ្ញុំ?

- អ្នកនឹងអាចជ្រើសរើសទីភ្នាក់ងារគ្រប់គ្រងករណីរបស់អ្នកពីបញ្ជីឈ្មោះដែលរដ្ឋផ្តល់ឱ្យ។
- ប្រសិនបើអ្នកមិនជ្រើសរើសទីភ្នាក់ងារទេ ទីភ្នាក់ងារមួយនឹងត្រូវបានជ្រើសរើសសម្រាប់អ្នក។

## តើ CFCM ប៉ះពាល់ដល់ខ្ញុំយ៉ាងដូចម្តេច?

- ប្រសិនបើអ្នកកំពុងទទួលបានសេវាកម្ម និងជំនួយគាំទ្ររបស់ HCBS រួចហើយ អ្នកមិនចាំបាច់ដាក់ពាក្យសុំម្តងទៀតទេ។ នៅពេលដែលអ្នកជ្រើសរើសទីភ្នាក់ងារគ្រប់គ្រងករណី ឬទីភ្នាក់ងារមួយត្រូវបានជ្រើសរើសសម្រាប់អ្នក CFCM នឹងជជែកជាមួយអ្នកអំពីតម្រូវការរបស់អ្នក។
- ប្រសិនបើអ្នកកំពុងដាក់ពាក្យសុំគម្រោង Medicaid ឬ LTSS អ្នកអាចទទួលបានជំនួយគាំទ្រដោយឥតគិតថ្លៃ និងមិនលម្អៀងពី The Point ដោយហៅទូរសព្ទទៅលេខ 401-462-4444។ ដើម្បីស្វែងយល់បន្ថែម សូមចូលទៅកាន់គេហទំព័រ oha.ri.gov/point។

## ហេតុអ្វី និងពេលណាដែលអ្វីៗត្រូវផ្លាស់ប្តូរ?

- ច្បាប់សហព័ន្ធចែងតម្រូវឱ្យអ្នកផ្តល់សេវាកម្មត្រូវតែធ្វើដាច់ដោយឡែកពីអ្នកគ្រប់គ្រងករណី។
- ការផ្លាស់ប្តូរនេះនឹងចាប់ផ្តើមសម្រាប់មនុស្សភាគច្រើននៅដើមឆ្នាំ 2024។
- អ្នកនឹងត្រូវបានទាក់ទងមុនពេលការផ្លាស់ប្តូរណាមួយបានធ្វើឡើងចំពោះករណីរបស់អ្នក។



ទោះបីជាមានការផ្លាស់ប្តូរជាមួយ CFCM ក៏ដោយ ក៏រឿងមួយនៅដដែល៖ **អ្នកផ្តល់សេវាកម្ម CFCM និង HCBS នៅទីនោះ ដើម្បីជួយអ្នកធ្វើអ្វីដែលសំខាន់បំផុតសម្រាប់អ្នក**។ ពួកគេនឹងធ្វើការជាមួយគ្នាដើម្បីធ្វើឱ្យប្រាកដថាអ្នកទទួលបានសេវាកម្មដែលអ្នកចង់បាន និងឆ្លើយតបទៅនឹងតម្រូវការផ្លាស់ប្តូររបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ eohhs.ri.gov/conflict-free-case-management។